**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** ..១១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតរាជាយស្ម័យយានកម្ពុជា ជាសហគ្រាសសាធារណៈ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តនីព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្នងការគណនី នៃសហគ្រាសសាធារណៈ
- យោងតាមលទ្ធផល នៃការប្រជុំអន្តរក្រសួង

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតសហគ្រាសសាធារណៈដែលមានទំរង់ជាក្រុមហ៊ុនរដ្ឋឈ្មោះ **រាជាយស្ម័យយានកម្ពុជា** សរសេរកាត់ "**រសយក**" ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន និង ក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**រសយក** មានទីស្នាក់ការនៅស្ថានីយ៍ធំភ្នំពេញ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ទីស្នាក់ការនេះ អាចផ្ទេរទៅកន្លែងផ្សេងទៀតតាមការចាំបាច់ ។

**រសយក** គឺជានីតិបុគ្គល មានស្វ័យភាព ផ្នែករដ្ឋបាល បច្ចេកទេស និង ផ្នែកហិរញ្ញវត្ថុ ។

**រសយក** ត្រូវស្ថិតក្រោមឥទ្ធិពល នៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ហើយត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ ស្តីពីលក្ខន្តិកៈ ទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងបទប្បញ្ញត្តិ នៃច្បាប់ពាណិជ្ជកម្ម ។

**មាត្រា ២.-**

**រសយក** ទទួលពីរដ្ឋនូវសិទ្ធិ និងភារកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

**រសយក** មានគោលដៅ និង ភារកិច្ច ដូចខាងក្រោម :

១- គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកទាំងមូលដែលមានស្រាប់ និង ផ្លូវដែកដែលត្រូវបានស្ថាបនាថ្មី ។

២- ជួសជុលថែទាំស្តារពង្រីកបណ្តាញគមនាគមន៍ផ្លូវដែក បណ្តាស្ថានីយ៍ អាគារ ទីលាន ចំណីផ្លូវ ទូរគមនាគមន៍ និង សិក្សាស្រាវជ្រាវលើកគំរោងទិសដៅអភិវឌ្ឍន៍ ។

៣- រ៉ាប់រងសេវាដឹកជញ្ជូនទំនិញ និង អ្នកដំណើរតាមផ្លូវដែក និង សិក្សាស្រាវជ្រាវលើកិច្ចអភិវឌ្ឍន៍វិស័យដឹកជញ្ជូនតាមផ្លូវដែក តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និង ទីផ្សារ ។

៤- គ្រប់គ្រង ថែទាំ ជួសជុល បំពាក់ថ្មី មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ បំរើអោយប្រសិទ្ធភាពទាំងបរិមាណ និង គុណភាពនៃសេវាដឹកជញ្ជូន ។

៥- ទទួលខុសត្រូវ និង ទទួលចាត់ចែងលើការងារការពារសណ្តាប់ធ្នាប់ សុវត្ថិភាព សន្តិសុខចរាចរ ខ្សែរថភ្លើងក្នុងតំបន់គ្រប់គ្រង ។

៦- ប្រកាន់គោលការណ៍ ធ្វើអាជីវកម្មដឹកជញ្ជូនដូចគ្នា នឹង អាជីវករ ។

៧- គ្រប់គ្រងដឹកនាំ និង ចាត់ចែងសកម្មភាពអាជីវកម្មអោយមានប្រសិទ្ធភាព និង ការអភិវឌ្ឍន៍ ។

**មាត្រា ៣.-**

លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ **អអយក** ត្រូវគោរពរបបពន្ធ និងអាករស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៤.-**

ដើមទុនដំបូងរបស់ **អអយក** ត្រូវកំណត់ឡើងតាមតុល្យការដំបូងដែលបានទទួលនូវការឯកភាពពី ក្រសួងសាធារណការ និង ដឹកជញ្ជូន និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ពេលដែលអនុក្រឹត្យនេះចូលជាធរមាន **អអយក** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋ លើទ្រព្យសម្បត្តិទាំងអស់ ដែលកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៥.-**

បុគ្គលិករបស់ **អអយក** ត្រូវជ្រើសរើសពីចំណោមមន្ត្រី នៃមុខងារសាធារណៈ របស់ក្រសួង សាធារណការ និងដឹកជញ្ជូន នឹងអាចជ្រើសរើសបុគ្គលិកខាងក្រៅ និង បុគ្គលិកជាប់កិច្ចសន្យាតាមការចាំបាច់ ។

បុគ្គលិករបស់ **អអយក** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈ ដោយឡែកអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី២
## ការដឹកនាំ និង ការគ្រប់គ្រង

**មាត្រា៦.-**

**អអយក** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិពេញលេញ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ បទប្បញ្ញត្តិ នៃអនុក្រឹត្យនេះ និង លក្ខន្តិកៈរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| -ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា | | ប្រធាន |
| -តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| -តំណាង ក្រសួងសាធារណការ និង ដឹកជញ្ជូន | ០១រូប | សមាជិក |
| -តំណាង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| -តំណាង ក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| -តំណាង ក្រសួងពាណិជ្ជកម្ម | ០១រូប | សមាជិក |
| -តំណាង និយោជិតរបស់ **អអយក** | ០១រូប | សមាជិក |

**មាត្រា៧.-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្មធ្លាប់បានបំរើការងារយ៉ាងតិច ០៥ឆ្នាំ (ប្រាំឆ្នាំ) ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យបច្ចេកទេស សេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬ នីតិសាស្ត្រ និង ជំនាញសមមូលផ្សេងទៀត ដែលមានសញ្ជាតិខ្មែរ និង មិនដែលមានទោសឧក្រិដ្ឋ ឬ មជ្ឈិម ពីរឿងល្មើសប៉ះពាល់ដល់ទំនៀមទំលាប់ កិត្តិយស និងភាពសុចរិត ។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ០៣ ឆ្នាំ ។ អាណត្តិនេះ អាចបញ្ចប់ និង អាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងអោយ ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិត **អអឃក** ។

**មាត្រា៨.-**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញដើម្បីសំរេចក្នុងនាម **អអឃក** ក្នុងការរៀបចំលិខិតស្នាម និង រាល់ឯកសារផ្សេងៗ ទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

**ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍ :**

១-ផ្តល់ការយល់ព្រមលើគំរោងផែនការសហគ្រាសដូចមានចែងក្នុងមាត្រា ១៦ នៃអនុក្រឹត្យនេះ ។

២-វាយតំលៃរៀងរាល់ពេលនូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលអោយបានសមស្របតាមសភាពការណ៍ ។

៣-ផ្តល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និង របាយការណ៍ស្តីពីសកម្មភាពរបស់ **អអឃក** ។

៤-សំរេចតាមសំណើរបស់ប្រធានអគ្គនាយកនូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្សរ៍ ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិកដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិទាំងឡាយជាធរមាន ។

៥-ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែល **អអឃក** ជាភាគីហត្ថលេខីស្របតាមលក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ជាជាធរមាន ។

៦-សំរេចបង្កើតបើក ឬ បិទការិយាល័យ និង ទីភ្នាក់ងារគ្រប់ទីកន្លែងរបស់ **អអឃក** តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧-កំណត់លើថ្លៃឈ្នួលពាក់ព័ន្ធ នឹងការធ្វើអាជីវកម្ម សេវាកម្ម ឧស្សាហកម្ម នៃ **អអឃក** ។

៨-ផ្តល់ការយល់ព្រមលើសំណើទិញផ្លាស់ប្តូរ ឬលក់ចលនទ្រព្យ និង អចលនទ្រព្យ ព្រមទាំងរាល់សំណើខ្ចីដោយមានវត្ថុបញ្ចាំ ឬ ការធានាផ្សេងៗ លើទ្រព្យសម្បត្តិរបស់សហគ្រាស ។

**មាត្រា៩.-**

ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេលវេលា អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាសតាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់សមាជិក ចំនួន ០៤ នាក់ យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។ ទោះបីជាយ៉ាងណាក៏ដោយក្រុមប្រឹក្សាភិបាល ត្រូវធ្វើការប្រជុំយ៉ាងតិច ០១ ដងក្នុងរយៈពេល ០៣ខែ។ ក្នុងករណីប្រធានមានធុរៈត្រូវជ្រើសរើសសមាជិកណាម្នាក់ តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ដែលមានវត្តមានដើម្បីដឹកនាំអង្គប្រជុំ ។

ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។ របៀបវារៈនៃការប្រជុំព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអោយបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបានលុះណាតែមានវត្តមានសមាជិកយ៉ាងតិច ០៤នាក់ ។

បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយ ដើម្បីពិភាក្សាឡើងវិញ លើបញ្ហាតាមរបៀបវារៈដដែល ។

កិច្ចប្រជុំលើកក្រោយនេះ មិនចាំបាច់ទាមទារកូរ៉ុមទេ ។ សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបានលុះណាតែមានការអនុម័តដោយសម្លេងភាគច្រើន នៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសម្លេងមានចំនួនស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

**មាត្រា១០.-**

សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និង ទៅមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ក្នុងរយៈពេល ១៥ថ្ងៃ យ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកក្រោយ ហើយត្រូវចំលងចូលបញ្ជីដែលមានលេខរៀង ទំព័រ ជាហូរហែរ និង មានអត្តលេខចំណាំត្រឹមត្រូវ ។ កំណត់ដើមត្រូវបានចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និង សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ដែលមានវត្តមាន និងលេខាធិការជ្រើសរើសដោយប្រធានអគ្គនាយក ។

**មាត្រា១១.-**

ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងការងារប្រក្រតីនៃ **អអយក** និង ត្រូវបានតែងតាំងសំរាប់អាណត្តិ ០៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។ តំណែងនេះបន្តទៀតបានតាមសំណើរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

**មាត្រា១២.-**

ក្រុមប្រឹក្សាភិបាលណែនាំនិងប្រគល់ជូនប្រធានអគ្គនាយក នូវអំណាចចាំបាច់ទាំងឡាយ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគ្រាសស្របតាមច្បាប់ ។

ក្នុងក្របខ័ណ្ឌនេះ ប្រធានអគ្គនាយកមានភារកិច្ច :

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសំរេច និងចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលតាមដំណាក់កាលនិមួយៗ។ ប្រធានអគ្គនាយក ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **អអយក** ។

២-ទទួលដឹកនាំ **អអយក** ផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម និង ហិរញ្ញវត្ថុ ។

៣-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬ បញ្ឈប់ការងារ និង មានសិទ្ធិត្រួតត្រាបណ្តាភ្នាក់ងារឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **អអយក** ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាន ។

៤-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬ ទាំងអស់រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខា ទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមលក្ខ័ខណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៥-តំណាងអោយ **អអយក** នឹងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ ក្នុងករណីចោទប្រកាន់តវ៉ាការពារក្តីអោយ **អអយក** និងការប្តឹងជំទាស់ផ្សេងៗ ។

**មាត្រា ១៣.-**

លាភការក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់ប្រធានអគ្គនាយក ត្រូវកំណត់ដោយក្រសួងអាណាព្យាបាល បច្ចេកទេស និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា១៤.-**

ការចុះ និង ការអនុវត្តន៍កិច្ចសន្យាដោយ **អអយក** ត្រូវគោរពតាមបែបបទ និង នីតិវិធីដែលកំណត់ដោយ លក្ខន្តិកៈរបស់សហគ្រាស និង ច្បាប់ជាធរមាន ។

# ជំពូកទី ៣
# ការគ្រប់គ្រង ហិរញ្ញវត្ថុ

**មាត្រា១៥.-**

**អអយក** កាន់កាប់គណនេយ្យរបស់ខ្លួនស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាន នៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំ ដដែល ។

របាយការណ៍ហិរញ្ញវត្ថុត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី ៣១ ខែ មិនា នៃការិយ បរិច្ឆេទបន្ទាប់ ។ របាយការណ៍ហិរញ្ញវត្ថុត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងកំឡុងពេល មិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ ។

**មាត្រា១៦.-**

រៀងរាល់ឆ្នាំមុនថ្ងៃទី ០១ ខែតុលា ក្រុមប្រឹក្សាភិបាល ត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការរបស់ **អអយក** តាមសំណើរបស់ប្រធានអគ្គនាយក ហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួង សាធារណការ និង ដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា១៧.-**

ធនធាន នៃ **អអយក** ជាអាទិ៍មាន :

- ដើមទុនដែលរដ្ឋផ្តល់អោយ ( តុល្យការដំបូងនៅពេលបង្កើត )
-ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទបានមកពីសកម្មភាពអាជីវកម្មរបស់ **អអយក**
-ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ **អអយក**
-ប្រាក់បានមកពីការខ្ចីបុល ប្រាក់អំណោយ និង ឧបត្ថម្ភធនផ្សេងៗ ។

**មាត្រា១៨.-**

**ចំណាយរបស់ អអយក រួមមាន :**

-ចំណាយប្រក្រតីសំរាប់ដំណើរការ
**-ចំណាយវិនិយោគ**
**-សងបំណុល**

-ចំណាយផ្សេងៗ ។

**មាត្រា១៩.-**

**អអយក** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

**មាត្រា២០.-**

**អអយក** ត្រូវបង់ប្រាក់ចំណេញប្រចាំឆ្នាំចូលថវិការដ្ឋចំនួន ៣០% (សាមសិបភាគរយ) ហើយរដ្ឋក៏អាចទុកប្រាក់ចំណេញនេះអោយសហគ្រាសផងដែរ ក្នុងករណីដែលរដ្ឋពិនិត្យឃើញថា សហគ្រាសត្រូវធ្វើការអភិវឌ្ឍន៍ចាំបាច់ ។ ប្រាក់ចំណេញដែលនៅសល់ក្រោយពីការបង់ចូលថវិការដ្ឋខាងលើ **អអយក** មានសិទ្ធិប្រើប្រាស់ អោយស្របតាមលក្ខន្តិកៈរបស់សហគ្រាស ។

**មាត្រា២១.-**

រដ្ឋធានាចំពោះបំណុលណាដែលមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ ការសាងសង់ និង ជួសជុលធំហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក ជាបន្ទុករបស់រដ្ឋ ។

**មាត្រា២២.-**

រយៈពេល ១៥ថ្ងៃយ៉ាងយូរក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **អអយក** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវឯកសារដូចតទៅក្រោមនេះ :

- កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់ **អអយក**
- របាយការណ៍ស្តីពីសកម្មភាពរបាយការណ៍ហិរញ្ញវត្ថុទាំងឡាយរបស់ **អអយក** ។

**មាត្រា២៣.-**

ត្រូវបានដាក់អោយនៅអម **អអយក** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសម្លេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទប្បញ្ញត្តិ នៃមាត្រា ១៩-២០-២១-[illegible] និង មាត្រា ២៤ នៃព្រះរាជក្រមលេខ ជ.ស/ រ.ក.ម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា២៤.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី-រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២៥
-ឯកសារ-កាលប្បវត្តិ